ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិធីអោយទំនោរជោគជ័យ

## ផែនការយុទ្ធសាស្ត្រ

ឆ្នាំសិក្សា ២០១៨-២០២៣

**សាកលវិទ្យាល័យ អង្គរ**

ANGKOR UNIVERSITY

# វិថីអេយូទំនោរជោគជ័យ

## ផែនការយុទ្ធសាស្ត្រ

**ឆ្នាំសិក្សា ២០១៨-២០២៣**

# **អារម្ភកថា**

ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាវិស័យអប់រំក៏ដូចជាវិស័យនានាមាន ការរីកចម្រើនទូទាំងប្រទេស ចាប់តាំងពីក្រុងរហូតដល់ជនបទ។ ដោយសារតែខេត្តសៀមរាប ជាតំបន់ទេសចរណ៍ និងមជ្ឈមណ្ឌលដ៏ធំមួយក្នុងការសាបព្រួសវប្បធម៌របស់កម្ពុជា **សម្តេច** ក៏បានផ្តល់អនុសាសន៍ដល់ឯកឧត្តម អ្នកឧកញ៉ា បណ្ឌិត **សៀង ណាំ** ឲ្យធ្វើយ៉ាងណាដើម្បីបង្កើនចំនួនធនធានមនុស្សប្រកបដោយ គុណភាពសម្រាប់បម្រើ ដល់វិស័យការងារក្នុងខេត្តសៀមរាប និងខេត្តជុំវិញ។ ជាងនេះទៀតក៏ដើម្បីរួមចំណែកបន្សីទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលអាណ្ណត្តិទី៦ សម្រាប់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ។ ដូចនេះ សាកលវិទ្យាល័យ អង្គរ ត្រូវបានបង្កើតឡើង និងទទួលស្គាល់ក្រោមអនុក្រឹត្យ លេខ ២៨ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល។

ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាភិបាលថ្មី ដែលប្រមូលផ្តុំទៅដោយសមាជិកជាឥស្សរជន បញ្ញាវន្ត អ្នកស្រាវជ្រាវ និងធុរជនដែលមានជំនាញច្បាស់លាស់ក្នុងការដឹកនាំសាកលវិទ្យាល័យឆ្ពោះទៅរកភាពរីកចម្រើន និង ជោគជ័យដែលជាមោទនភាពមួយក្នុងខេត្តសៀមរាប ។ រចនាសម្ព័ន្ធថ្មីនៃក្រុមប្រឹក្សាភិបាលដែលមានសមាសភាព ៧ រូប ក្នុងនោះសិទ្ធអំណាចនិងលំហូរការងារត្រូវបានកំណត់ច្បាស់លាស់ ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យ បេសកកម្ម និងគោលបំណងរបស់សាកលវិទ្យាល័យព្រមទាំងធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងនិរន្តរភាព ស្ថាប័ន ជាងនេះទៀតក្នុងគោលបំណងបត់បែន ទៅតាមបរិបទថ្មី ជាពិសេសក្នុងយុគសម័យនៃការប្រកួតប្រជែង ធានាការផ្តល់សេវាកម្មអប់រំប្រកបដោយគុណភាពនៅក្នុងតំបន់។

ឈរលើមូលដ្ឋាននេះទើប សាកលវិទ្យាល័យ **អង្គរ** រៀបចំផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ (២០១៨-២០២៣) ដោយផ្តោតទៅលើការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព ស្របទៅតាមទីផ្សារ ក្នុងស្រុក តំបន់ និងអន្តរជាតិការបង្កើតប្រព័ន្ធគ្រប់គ្រងបែបទំនើប និងការជំរុញការស្រាវជ្រាវនិងការផ្លាស់ប្តូរវប្បធម៌រវាងអ្នកសិក្សាស្រាវជ្រាវទូទៅ។

តាំងនាមឲ្យក្រុមប្រឹក្សាភិបាល សូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យនៃសាកលវិទ្យាល័យអង្គរ ដែលបានខិតខំទាំង កម្លាំងកាយ និងកម្លាំងចិត្តក្នុងការបង្កើតធនធានមនុស្សគ្រប់កម្រិតឲ្យមានសមត្ថភាពខ្ពស់ ប្រកបដោយភាពជាអ្នកដឹកនាំ ច្នៃប្រឌិត និងនវានុវត្តតាមរយៈការផ្តល់ចំណេះដឹង ចំណេះធ្វើ រួមទាំង ជំនាញផ្នែករឹង ផ្នែកទន់ ដែលអនុញ្ញាតិឲ្យពួកគេអាចបំពេញ ឲ្យតម្រូវការទីផ្សារការងារជាតិ និងអន្តរជាតិស្របតាមតម្លៃស្នូលរបស់សាកលវិទ្យាល័យ ក្នុងបរិបទនៃការប្រកួតប្រជែង និងបម្រែបម្រួលស្ថានភាពសាកល ។ ក្រៅពីនេះខ្ញុំសូមជូនពរដល់គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យ ព្រមទាំងនិស្សិតទាំងអស់នៃសាកលវិទ្យាល័យ អង្គរ មានសុខភាពល្អ និងរីករាយក្នុងជីវិតផ្ទាល់ខ្លួន គ្រួសារ និងសង្គមជាតិ។

ថ្ងៃ.........................ខែ.....................ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

សៀមរាប ថ្ងៃទី...............ខែ.............ឆ្នាំ ២០១៨

**ប្រធានក្រុមប្រឹក្សាភិបាល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យ អង្គរ

លេខ ០៣៧០/១៩ ស.អ

# រចនាសម្ព័ន្ធចាត់តាំង ក្រុមប្រឹក្សាភិបាល សាកលវិទ្យាល័យ អង្គរ

**ឯកឧត្តម បណ្ឌិត សៀង ណាំ**
**ប្រធាន**

**លោក សុខ តុញ**
**អនុប្រធាន**

**លោក ម៉េង ហ៊ាង**
**សមាជិក**

**លោក ហៀក សុវណ្ណារិទ្ធ**
**សមាជិក**

**បណ្ឌិត ញិល េង្គា**
**សមាជិក**

ថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
សៀមរាប ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៩
ជ.ក្រុមប្រឹក្សាភិបាល
អនុប្រធាន

សុខ តុញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យ អង្គរ
លេខ ០៣៧៩/១៩ ស.អ

# រចនាសម្ព័ន្ធអភិបាលកិច្ចសាកលវិទ្យាល័យ អង្គរ

- ក្រុមប្រឹក្សាភិបាល
  - សាកលវិទ្យាធិការ
    - ការិយាល័យ ធានាគុណភាពអប់រំផ្ទៃក្នុង
    - ទីប្រឹក្សា
    - សាកលវិទ្យាធិការរង ទទួលបន្ទុកកិច្ចការសិក្សា និងសេវានិស្សិត
      - មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
      - មហាវិទ្យាល័យ សុខភាពសាធារណៈ
      - មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
      - មហាវិទ្យាល័យ មនុស្សសាស្ត្រ និងភាសាបរទេស
      - មហាវិទ្យាល័យ សង្គមសាស្ត្រ និងនីតិសាស្ត្រ
      - មហាវិទ្យាល័យ កសិកម្ម
      - មហាវិទ្យាល័យ វិស្វកម្ម និងស្ថាបត្យកម្ម
      - ការិយាល័យសិក្សា
      - ការិយាល័យ ថ្នាក់ក្រោយឧត្តម
      - ការិយាល័យ ប្រឡង
      - មជ្ឈមណ្ឌល ភាសាបរទេស
      - មជ្ឈមណ្ឌល ស្មាតធិច
    - សាកលវិទ្យាធិការរង ទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុ
      - ការិយាល័យ គណនេយ្យ និងហិរញ្ញវត្ថុ
      - ការិយាល័យ សវនកម្ម
      - ការិយាល័យ រដ្ឋបាល និងធនធានមនុស្ស
    - សាកលវិទ្យាធិការរង ទទួលបន្ទុកទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
      - ការិយាល័យ ព័ត៌មាន ទីផ្សារ និងទំនាក់ទំនងអន្តរជាតិ
      - ការិយាល័យ ស្រាវជ្រាវ និងបោះពុម្ពផ្សាយ
      - ការិយាល័យ បច្ចេកវិទ្យាព័ត៌មាន
      - បណ្ណាល័យ

ថ្ងៃអង្គារ ០៦ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
សៀមរាប ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៩
សាកលវិទ្យាធិការ ជ.ស

បណ្ឌិត ញឹល រដ្ឋា

# មាតិកា

អារម្ភកថា
របនាសម្ព័ន្ធចាត់តាំង ក្រុមប្រឹក្សាភិបាល
របនាសម្ព័ន្ធអភិបាលកិច្ច
សេចក្តីផ្តើម ------------------------------------------------------------------------------------------------------------ ០២
លទ្ធផលសំខាន់ៗ និងបញ្ហាប្រឈម------------------------------------------------------------------------------------------ ០៣
ជំពូកទី ១ ៖ ចក្ខុវិស័យ បេសកកម្ម និងតម្លៃស្នូល --------------------------------------------------------------------------- ០៤
ជំពូកទី ២ ៖ គោលបំណង ------------------------------------------------------------------------------------------------ ០៥
ជំពូកទី ៣ ៖ ក្របខ័ណ្ឌគោលដៅយុទ្ធសាស្ត្រ---------------------------------------------------------------------------------- ០៦
១. ការពង្រឹងការគ្រប់គ្រងប្រកបដោយភាពជាអ្នកដឹកនាំ--------------------------------------------------------------------- ០៦
២. ការបង្កើនគុណភាពអប់រំប្រកបដោយនិរន្តរភាព -------------------------------------------------------------------------- ០៨
៣. ការស្រាវជ្រាវ និងការអភិវឌ្ឍ------------------------------------------------------------------------------------------ ១៣
៤. ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ------------------------------------------------------------- ១៤
៥. ការទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ និងអន្តរជាតិ -------------------------------------------------------------- ១៦
ជំពូកទី ៤ ៖ ផែនការសកម្មភាព------------------------------------------------------------------------------------------- ១៨
ជំពូកទី ៥ ៖ ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង --------------------------------------------------------------------------------- ៦០
ជំពូកទី ៦ ៖ ការពិនិត្យ តាមដាន និងវាយតម្លៃ------------------------------------------------------------------------------ ៦២
ការសន្និដ្ឋាន ---------------------------------------------------------------------------------------------------------- ៦៣

# សេចក្តីផ្តើម

ការប្រែប្រួលនៃបរិបទសង្គមជាសាកល និងដោយឡែក ជាពិសេសកំណើនសេដ្ឋកិច្ចខ្ពស់ជាបន្តបន្ទាប់ ព្រមទាំងការវិនិយោគបរទេសក្នុងវិស័យនានារបស់ព្រះរាជាណាចក្រកម្ពុជាជាកត្តាធ្វើឲ្យមានតម្រូវការចំពោះកម្លាំងពលកម្មជាពិសេសកម្រិតឧត្តមសិក្សា និងក្រោយឧត្តមជាដើម។ សាកលភាវូបនីយកម្ម និងតំបន់នីយកម្ម ជាកត្តាចម្បងដែលនាំឲ្យជំនាញសំខាន់ៗត្រូវការសិក្សាជាចាំបាច់ដើម្បីបម្រើដល់ទីផ្សារការងារដោយជោគជ័យ ដែលមានជាអាទិ៍ ជំនាញផ្នែកទន់(ជំនាញបញ្ញាផ្លូវអារម្មណ៍) និងជំនាញបច្ចេកទេស (ជំនាញផ្នែករឹង)។

ដើម្បីឆ្លើយតបតម្រូវការទីផ្សារការងារដែលស្របតាមភូមិសាស្ត្រសង្គម និងបរិបទសហគមន៍សេដ្ឋកិច្ចអាស៊ាន ផែនការចតុកោណ ផែនការអប់រំជាតិ សាកលវិទ្យាល័យ អង្គរ មានកម្មវិធីអប់រំ ដែលស្របតាមស្តង់ដារអប្បបរមាសម្រាប់វាយតម្លៃគុណភាពអប់រំផ្ទៃក្នុងផ្តោតសំខាន់លើការ ផ្តល់គុណភាពសិក្សា បង្រៀន និងស្រាវជ្រាវ ចំណេះដឹង ជំនាញបញ្ញាផ្លូវអារម្មណ៍ ជំនាញបច្ចេកទេស ភាសាអង់គ្លេស ភាសាបរទេសផ្សេងៗ បច្ចេកវិទ្យាពត៌មានវិទ្យា មានឥរិយាបថល្អ ចេះសិក្សា និងស្រាវជ្រាវដោយខ្លួនឯង និងមានទំនុកចិត្តលើខ្លួនឯង បំពេញឲ្យតម្រូវការទីផ្សារការងារអាស៊ាន និងតំបន់ សំដៅអភិវឌ្ឍជីវិត គ្រួសារ និងសង្គម។

ក្រៅពីនេះសាកលវិទ្យាល័យ អង្គរ បានកំណត់គោលដៅយុទ្ធសាស្ត្រដូចតទៅ ៖

I. ការពង្រឹងការគ្រប់គ្រងប្រកបដោយភាពជាអ្នកដឹកនាំ
II. ការបង្កើនគុណភាពអប់រំ
III. ការស្រាវជ្រាវ និងការអភិវឌ្ឍ
IV. ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
V. ការទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ និងអន្តរជាតិ ។

ផែនការយុទ្ធសាស្ត្រនេះមានវិសាលភាពគ្របដណ្តប់លើដំណើរការនៃការគ្រប់គ្រង និងប្រតិបត្តិការនៃអង្គភាពចំណុះទាំងអស់សកលវិទ្យាល័យ **អង្គរ** ដើម្បីសម្រេចបានចក្ខុវិស័យ បេសកកម្ម និងគោលដៅយុទ្ធសាស្ត្រ សម្រាប់រយៈពេល ២០១៨-២០២៣។

## លទ្ធផលសំខាន់ៗ និងបញ្ហាប្រឈម

ផ្អែកតាមផែនការយុទ្ធសាស្ត្រ លេខ ១៩៥ ស.អ. ចុះថ្ងៃទី ០១ មិថុនា ឆ្នាំ ២០១៤ ស្តីពី ការកែតម្រូវលើផែនការ យុទ្ធសាស្ត្រ ២០១៣-២០១៨ របស់សាកលវិទ្យាល័យ អង្គរ បានបង្ហាញឲ្យឃើញថាគ្រឹះស្ថាននេះបានពង្រីកខ្លួនបន្ថែមពីការ បណ្តុះបណ្តាលជំនាញទូទៅ ទៅកាន់ផ្នែកសុខាភិបាល ដែលមានតែមួយគត់ ក្នុងតំបន់សៀមរាប និងបានបង្កើតកម្លាំងពលកម្មអាជីពសម្រាប់តម្រូវការទីផ្សារការងារកម្ពុជាប្រកបដោយគុណភាពខ្ពស់ ។

សាកលវិទ្យាល័យ អង្គរ បានបណ្តុះបណ្តាលធនធានមនុស្សផ្នែកគិលានុប្បដ្ឋាក និងឆ្មប ដែលកំពុងបម្រើការងារ ក្នុងមន្ទីរពេទ្យ មណ្ឌលសុខភាព និងគ្លីនិកឯកជនជាច្រើនក្នុងខេត្តសៀមរាប ក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ក្នុងកំឡុងពេលនៃផែនការយុទ្ធសាស្ត្រនេះ និស្សិតគ្រប់ជំនាញដែលបញ្ចប់ការសិក្សា និងទទួលសញ្ញាបត្ររួច មានចំនួន ៥៩៣នាក់ ស្រី១៣៦នាក់ និស្សិតដែលបានបញ្ចប់ការសិក្សា និងមិនទាន់ទទួលសញ្ញាបត្ររួច មានចំនួន២៣៨នាក់ ស្រី ៧៧នាក់ និង បានបញ្ចប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ មានចំនួន ២៩នាក់ ស្រី ០៥នាក់។

យុទ្ធសាស្ត្រទាំង ៩ (២០១៣-២០១៨) ដែលបានអនុវត្តកន្លងមកបានជោគជ័យជាង ៦០ភាគរយ ដូចជា មានការរៀបចំផែនការនិងរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំ ការផ្លាស់ប្តូររចនាសម្ព័ន្ធនៃការគ្រប់គ្រង ការកែលម្អកម្មសិក្សា ការជ្រើសរើសវាយតម្លៃនិងលើកទឹកចិត្តសាស្ត្រាចារ្យ ការពង្រឹងគុណភាពបណ្តុះបណ្តាល ការធ្វើទំនើបកម្មសេវាសិក្សា ការគ្រប់គ្រងសម្ភារៈរូបវន្ត ការរៀបចំរបាយការហិរញ្ញវត្ថុ និងការបង្កើនការទំនាក់ទំនងនិងផ្សព្វផ្សាយជាមួយសិស្សានុសិស្ស និស្សិត សាធារណៈជន អ្នកសិក្សាទូទៅ និងដៃគូដែលពាក់ព័ន្ធ។

ប៉ុន្តែទោះជាលទ្ធផលនៃការអនុវត្តការងារក្នុងរយៈពេល ៥ ឆ្នាំ(២០១៣-២០១៨) នេះមានភាពជោគជ័យមួយកម្រិតក៏ដោយក៏សាកលវិទ្យាល័យ ជួបបញ្ហាប្រឈមដូចតទៅ ៖

- ការអនុវត្តការងារតាមផែនការនៅមានកម្រិត
- ការផ្លាស់ប្តូរគណៈគ្រប់គ្រង ២ លើក ដោយសារបញ្ហានិរន្តរភាពនៃការបណ្តុះបណ្តាល
- ការលើកទឹកចិត្តសាស្ត្រាចារ្យនៅចោទជាបញ្ហា
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៅមានកម្រិតក្រោមស្តង់ដារ និង
- ការទំនាក់ទំនងនិងផ្សព្វផ្សាយជាមួយសិស្សានុសិស្ស និស្សិត សាធារណៈជន អ្នកសិក្សាទូទៅ និងដៃគូដែលពាក់ព័ន្ធនៅមានកម្រិតទាបនៅក្នុងបរិបទនៃការប្រកួតប្រជែង។

## ជំពូក ១

# ចក្ខុវិស័យ បេសកកម្ម និងគម្លៃស្នូល

### ១. ចក្ខុវិស័យ (VISION)

សាកលវិទ្យាល័យ អង្គរ នឹងក្លាយជាគ្រឹះស្ថានអប់រំដែលបង្កើតកម្លាំងពលកម្មអាជីពសម្រាប់តម្រូវការ ទីផ្សារការងារកម្ពុជា និងអាស៊ានប្រកបដោយភាពជាអ្នកដឹកនាំ ច្នៃប្រឌិត និងនវានុវត្ត ស្របតាមបរិបទសាកលភាវូបនីយកម្ម។

### ២. បេសកកម្ម (MISSION)

- បណ្តុះបណ្តាលជំនាញផ្សេងៗស្របតាមតម្រូវការទីផ្សារការងារជាតិ និងអន្តរជាតិ
- ផលិតធនធានមនុស្សប្រកបដោយគុណភាព និងឧត្តមភាព
- ផ្តល់បរិយាកាសនៃការអប់រំ ការសិក្សា ការស្រាវជ្រាវ និងការអភិវឌ្ឍពេញមួយជីវិត។

### ៣. គម្លៃស្នូល (CORE VALUE)

### ៣.១- គុណភាព

សំដៅដល់និស្សិតដែលមាន ៖

- សុច្ចរិតភាព
  - ភាពជឿជាក់
  - ភាពស្មោះត្រង់
  - ភាពទទួលខុសត្រូវ
- នវានុវត្តភាព
  - ការគិតដោយភាពច្នៃប្រឌិត
  - ការបង្កើតឱកាស
  - និរន្តរភាព
- ការចូលរួមសកម្មភាពសង្គម
  - គណនេយ្យភាព
  - ការប្តេជ្ញាចិត្ត
  - ការស្ម័គ្រចិត្ត

### ៣.២- ពុទ្ធិ

សំដៅដល់និស្សិតដែលមាន ៖

- ភាពរីកចម្រើន និងការអភិវឌ្ឍ
- ការទំនាក់ទំនងល្អក្នុងគ្រួសារ និងសង្គម
- សុខភាព សុវត្ថិភាព និងគុណភាពជីវិត

### ៣.២- សីលធម៌

សំដៅដល់និស្សិតដែលមាន ៖

- ភាពចុះសម្រុងគ្នា
- ភាពថ្លៃថ្នូរក្នុងសង្គម
- ស្មារតី និងមនសិការស្នេហាជាតិ

**ជំពូក ២**

# គោលបំណង

ដើម្បីបង្កើតធនធានមនុស្សគ្រប់កម្រិតឲ្យមានសមត្ថភាពខ្ពស់ ប្រកបដោយភាពជាអ្នកដឹកនាំ ច្នៃប្រឌិត និងនវានុវត្តតាមរយៈការផ្តល់ចំណេះដឹង ចំណេះធ្វើ រួមទាំង ជំនាញផ្នែកទន់ ដែលអនុញ្ញាតិឲ្យពួកគេអាចបំពេញ ឲ្យតម្រូវការទីផ្សារការងារជាតិ និងអន្តរជាតិស្របតាមតម្លៃស្នូលរបស់សាកលវិទ្យាល័យ ក្នុងបរិបទនៃការប្រកួតប្រជែង និងបម្រែបម្រួលស្ថានភាពសាកល សាកលវិទ្យាល័យអង្គរ បានកំណត់គោលបំណងចំនួន ៥ ដូចតទៅ ៖

- ពង្រឹងការគ្រប់គ្រងប្រកបដោយភាពជាអ្នកដឹកនាំសម្រាប់ធានាការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល
- បង្កើនគុណភាពអប់រំប្រកបដោយនិរន្តរភាព ស្របតាមបរិបទនៃការប្រកួតប្រជែង និងបម្រែបម្រួលស្ថានភាពសាកល
- បង្កើត និងបង្កើនសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍ
- ពង្រីកដៃគូទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិដើម្បីបង្កើនកម្រិតស្តង់ដារអប់រំខ្ពស់ និងពង្រីកកិត្យានុភាពរបស់សាកលវិទ្យាល័យ
- វាយតម្លៃគុណភាពអប់រំថ្នាក់ជាតិ និងអន្តរជាតិដើម្បីធានាការគ្រប់គ្រង ការបណ្តុះបណ្តាល និងការសិក្សាប្រកប ដោយគុណភាព និងនិរន្តរភាព

## ជំពូក ៣

# ក្របខ័ណ្ឌគោលដៅយុទ្ធសាស្ត្រ

នៅក្នុងការធានាការផ្តល់គុណភាពបង្រៀន សិក្សា និងស្រាវជ្រាវ ប្រកបដោយចំណេះដឹង ជំនាញបញ្ញាផ្លូវអារម្មណ៍ ជំនាញបច្ចេកទេស ភាសាបរទេស បច្ចេកវិទ្យាព័ត៌មានវិទ្យាខ្ពស់ មានឥរិយាបថល្អ ចេះសិក្សាស្រាវជ្រាវដោយខ្លួនឯង និងមានទំនុកចិត្តលើខ្លួនឯង ដើម្បីបម្រើការក្នុងទីផ្សារការងារជាតិ និងអន្តរជាតិ សម្រាប់ចិញ្ចឹមជីវិតផ្ទាល់ខ្លួន គ្រួសារ និងសង្គមប្រកបដោយអារ្យធម៌ខ្ពស់ សាកលវិទ្យាល័យ មានកំណត់គោលដៅជាយុទ្ធសាស្ត្រអាទិភាពដូចខាងក្រោម ៖

I. ការពង្រឹងការគ្រប់គ្រងប្រកបដោយភាពជាអ្នកដឹកនាំ
II. ការបង្កើនគុណភាពអប់រំប្រកបដោយនិរន្តរភាព
III. ការស្រាវជ្រាវ និងការអភិវឌ្ឍ
IV. ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
V. ការទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ និងអន្តរជាតិ ។

## ១.១- ការពង្រឹងការគ្រប់គ្រងប្រកបដោយភាពជាអ្នកដឹកនាំ

ការពង្រឹងនីតិវិធី និងអភិបាលកិច្ចល្អ គឺជាចំណុចយ៉ាងសំខាន់របស់គ្រឹះស្ថានឧត្តមសិក្សាតាមរយៈយន្តការដឹកនាំជាប្រព័ន្ធ មានតម្លាភាព គណនេយ្យភាព និងសុក្រិតភាព ធានាដល់ការបង្កើតគុណភាពអប់រំ ឲ្យឆ្លើយតបទៅនឹងស្តង់ដារជាតិ និងអន្តរជាតិ។ ដូច្នេះ ដើម្បីធានាគុណភាពអប់រំស្របតាមស្តង់ដារជាតិ និងអន្តរជាតិ សាកលវិទ្យាល័យ អង្គរ បានកំណត់ទិសដៅយុទ្ធសាស្ត្រសំខាន់ៗចំនួន ០៥ ដូចខាងក្រោម៖

1) ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចច្បាស់លាស់
2) ការលើកកម្ពស់សមត្ថភាពបុគ្គលិក និងការលើកទឹកចិត្ត
3) ការរៀបចំយន្តការដឹកនាំ គ្រប់គ្រង និងប្រតិបត្តិការច្បាស់លាស់
4) ការកំណត់ប្រព័ន្ធតាមដាន វាយតម្លៃជាក់លាក់
5) ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ។

### ១.១.១- ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចច្បាស់លាស់

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- មានប្រព័ន្ធគ្រប់គ្រងរួម និងដោយឡែក ដែលបញ្ជាក់ពីសិទ្ធអំណាច និងលំហូរការងារច្បាស់លាស់ ឆ្លើយតបទៅនឹងចក្ខុវិស័យ បេសកកម្ម និងគោលបំណងរបស់សាកលវិទ្យាល័យ ព្រមទាំងធានាប្រសិទ្ធភាព នៃការគ្រប់គ្រង និងនិរន្តរភាពស្ថាប័ន
- ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាបណ្តុះបណ្តាល គណៈកម្មការនានា មានចំនួន ស្របតាមរចនាសម្ព័ន្ធ គ្រប់គ្រងរួម និងដោយឡែករបស់សាកលវិទ្យាល័យ
- កំណត់ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាបណ្តុះបណ្តាល គណៈកម្មការនានា ថ្នាក់ដឹកនាំ បុគ្គលិក ស្របតាមរចនាសម្ព័ន្ធគ្រប់គ្រង និងគាំទ្រផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ

- ធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិក ឆ្លើយតបទៅនឹង គោលនយោបាយជាតិ និងបរិបទអប់រំអាស៊ាន ហើយធានាប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រង និងប្រតិបត្តិការរបស់ក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ
- ធ្វើវិសោធនកម្មគោលនយោបាយ ឬ គោលការណ៍និងនីតិវិធីស្តីពីការជ្រើសរើស វាយតម្លៃ លើកទឹកចិត្ត និងអភិវឌ្ឍបុគ្គលិក និងក្រុមប្រឹក្សាភិបាល ឆ្លើយតបទៅនឹងគោលនយោបាយជាតិ បរិបទអប់រំ និងទីផ្សារការងារអាស៊ាន ដែលមានតម្លាភាព គុណភាព ប្រសិទ្ធភាពខ្ពស់ និងធានានិរន្តរភាពស្ថាប័ន
- មានគោលការណ៍ នីតិវិធី និងទម្រង់បែបបទផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពរយៈពេល ០៥ ឆ្នាំ ផែនការសកម្មភាពប្រចាំឆ្នាំ និងប្រចាំខែ ស្របតាមគោលនយោបាយជាតិ និងអន្តរជាតិ
- មានផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពរយៈពេល ០៥ឆ្នាំ ផែនការសកម្មភាពប្រចាំឆ្នាំ និងខែច្បាស់លាស់ស្របតាមគោលការណ៍ នីតិវិធី និងទម្រង់បែបបទរបស់សាកលវិទ្យាល័យ ហើយត្រូវបានស្ថាប័ន អង្គភាពចំណុះ និងអ្នកពាក់ព័ន្ធចូលរួមពិគ្រោះយោបល់ ព្រមទាំងយល់ដឹងទូលំទូលាយ ។

## ១.១.២- ការលើកកម្ពស់សមត្ថភាពបុគ្គលិក និងការលើកទឹកចិត្ត

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- បុគ្គលិក និងក្រុមប្រឹក្សាភិបាល បានជ្រើសរើស វាយតម្លៃ លើកទឹកចិត្ត និងអភិវឌ្ឍស្របតាមគោលការណ៍ និងនិតិវិធីរបស់សាកលវិទ្យាល័យ
- ក្រុមប្រឹក្សាភិបាលមានសញ្ញាបត្របណ្ឌិតយ៉ាងតិចចំនួន ៥០ ភាគរយ បរិញ្ញាបត្រជាន់ខ្ពស់ ៣០ ភាគរយ និងបរិញ្ញាបត្រ ២០ ភាគរយនៃចំនួនសរុប
- អ្នកគ្រប់គ្រងថ្នាក់កំពូលមានសញ្ញាបត្របណ្ឌិតចំនួន ៧០%
- អ្នកគ្រប់គ្រងថ្នាក់កណ្តាលរួមមានៈ ព្រឹទ្ធបុរស នាយកវិទ្យាស្ថាន នាយកសាលាជាន់ខ្ពស់ និងប្រធានដេប៉ាតឺម៉ង់ មានសញ្ញាបត្របណ្ឌិតចំនួន ៥០ ភាគរយ ព្រមទាំងនាយកមជ្ឈមណ្ឌល បណ្ណាល័យ និងប្រធានការិយាល័យ ជាដើម មានសញ្ញាបត្របណ្ឌិតចំនួន ៣០% ភាគរយ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៧០%
- អ្នកគ្រប់គ្រងថ្នាក់ក្រោមមានបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៥០%
- បុគ្គលិកប្រតិបត្តិការការងារជំនាញមានបរិញ្ញាបត្រចំនួន ៥០ភាគរយ និងបុគ្គលិកប្រតិបត្តិការការងារ សន្តិសុខ និងអនាម័យមានកម្រិតវប្បធម៌សមស្រប
- អភិវឌ្ឍសមត្ថភាពដោយផ្តល់អាហារូបករណ៍ និងការចូលរួមសិក្ខាសាលា ដើម្បីសិក្សាបង្កើនគុណវុឌ្ឍិ និងពង្រីកសមត្ថភាពនៅក្នុង និង/ឬ ក្រៅប្រទេស
- ថ្នាក់ដឹកនាំនិងបុគ្គលិកសាកលវិទ្យាល័យមានសមត្ថភាពភាសាអង់គ្លេសអាចប្រើប្រាស់ជាផ្លូវការ ព្រមទាំងអាចប្រើប្រាស់ ICT យ៉ាងស្ទាត់ជំនាញ ។

## ១.១.៣- ការដឹកនាំ គ្រប់គ្រង និងអនុវត្តប្រកបដោយភាពច្បាស់លាស់

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- អនុវត្តការងារដោយរលូនស្របតាមតួនាទី និងភារកិច្ចរបស់បុគ្គលិកតាមលំដាប់ថ្នាក់ជាប្រចាំ
- បង្កើតយន្តការងារដែលមានប្រសិទ្ធភាពខ្ពស់ក្នុងបរិបទបច្ចេកវិទ្យាទំនើបស្របតាមរចនាសម្ព័ន្ធច្បាស់លាស់

### ១.១.៤- ការបង្កើត និងអភិវឌ្ឍយន្តការតាមដានត្រួតពិនិត្យ វាយតម្លៃ និងលើកទិសដៅ

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ពន្យល់ណែនាំពីគោលការណ៍នានាដែលពាក់ព័ន្ធនឹងការតាមដានត្រួតពិនិត្យដល់បុគ្គលិកក្រោមឱវាទ
- តាមដាន ត្រួតពិនិត្យ និងកែលម្អដល់បុគ្គលិកតាមលំដាប់ថ្នាក់ជាប្រចាំ
- វាយតម្លៃការអនុវត្តផែនការ និងលើកទិសដៅ ស្របតាមគោលការណ៍ និងនីតិវិធីរបស់សាកលវិទ្យាល័យ ។

### ១.១.៥- ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពខ្ពស់

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- មានប្រព័ន្ធគណនេយ្យស្តង់ដារអន្តរជាតិកម្ពុជា
- មានគោលការណ៍ នីតិវិធី និងទម្រង់បែបបទស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ស្របតាមស្តង់ដារជាតិ និងអន្តរជាតិ
- គ្រប់គ្រង និងប្រតិបត្តិការប្រព័ន្ធគណនេយ្យស្របតាមមានគោលការណ៍ នីតិវិធី និងទម្រង់បែបបទ
- មានរបាយការណ៍ហិរញ្ញវត្ថុ ស្របតាមស្តង់ដារជាតិ និងអន្តរជាតិ ច្បាស់លាស់
- ធ្វើសវនកម្មផ្ទៃក្នុង និងខាងក្រៅ ស្របតាមមានគោលការណ៍ និងនីតិវិធី ។

### ១.២- ការបង្កើនគុណភាពអប់រំប្រកបដោយនិរន្តរភាព

គុណភាពអប់រំកម្រិតឧត្តមសិក្សា ក្រោយឧត្តមសិក្សា មានសារៈសំខាន់ដើម្បីអភិវឌ្ឍធនធានមនុស្សឲ្យមានចំណេះដឹង ចំណេះធ្វើ ជំនាញទាំងផ្នែករឹង ទន់ ស្របតាមតម្រូវការទីផ្សារការងារជាតិ និងអន្តរជាតិ ព្រមទាំងអភិវឌ្ឍសង្គមសេដ្ឋកិច្ច នៅក្នុងបរិបទនៃការប្រកួតប្រជែង។ យោងតាមលក្ខខណ្ឌទាំងនេះ គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវរៀបចំ កែលម្អ និងការអភិវឌ្ឍកម្មវិធីអប់រំឲ្យឆ្លើយតបទៅនឹងទីផ្សារការងារ ជាតិ និងអន្តរជាតិ សំដៅជំរុញនិស្សិត គ្រប់កម្រិតសិក្សាឲ្យទទួលបានការងារធ្វើស្របតាមលទ្ធផលរំពឹងទុក។ ការជ្រើសរើស និងសម្រិតសម្រាំងគ្រូបង្រៀនដែលមានគុណវុឌ្ឍិ បទពិសោធបង្រៀន និងការងារជាក់ស្តែង ការរៀបចំយន្តការថែរក្សាគ្រូបង្រៀន មានសារៈសំខាន់ណាស់នៅក្នុងការធានាគុណភាពអប់រំ ដើម្បីឲ្យឆ្លើយតប ទៅនឹងតម្រូវការនៃកម្មវិធីអប់រំនៃឯកទេសនីមួយៗ។ ការបំពាក់ធនធានសិក្សា និងធនធានរូបវន្ត សម្រាប់គាំទ្រដល់ការបង្រៀន សិក្សា និងស្រាវជ្រាវ នៃមុខវិជ្ជានីមួយៗ ដើម្បីសម្រេចតាមបានចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់ព្រមទាំង លទ្ធផលរំពឹងទុកនៃកម្មវិធីសិក្សានីមួយៗ។ ហេតុដូចនេះ សាកលវិទ្យាល័យ អង្គរ បានកំណត់ទិសដៅយុទ្ធសាស្ត្រ សំខាន់ៗចំនួន ០៥ ដូចខាងក្រោម ៖

1) ការអភិវឌ្ឍកម្មវិធីសិក្សាស្តង់ដាជាតិ និងអន្តរជាតិ
2) ការអភិវឌ្ឍសមត្ថភាព និងគុណភាពបង្រៀនរបស់គ្រូបង្រៀន/សាស្ត្រាចារ្យ
3) ការអភិវឌ្ឍសម្ភារៈរូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ
4) ការលើកកម្ពស់គុណភាពសិក្សា និងការស្រាវជ្រាវ
5) ការបង្កើនគុណភាពការផ្តល់សេវាកម្មនិស្សិត ។

### ១.២.១- ការអភិវឌ្ឍកម្មវិធីសិក្សាស្របតាមស្តង់ដាជាតិ និងអន្តរជាតិ

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- មានសេចក្តីសម្រេចស្តីពីការរៀបចំ និងការអភិវឌ្ឍកម្មវិធីអប់រំកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់
- សិក្សាស្រាវជ្រាវពីបញ្ហាប្រឈមរបស់ និស្សិតបញ្ចប់ការសិក្សានៃឯកទេសនីមួយៗ
- ស្រាវជ្រាវតម្រូវការទីផ្សារការងារពីសហគ្រិន ដូចជាស្ថាប័នរដ្ឋ ឯកជន អង្គការជាតិ និងអន្តរជាតិ

- អភិវឌ្ឍកម្មវិធីសិក្សា ស្របតាមគោលការណ៍និងនីតិវិធីស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា ដោយផ្សារភ្ជាប់ ការស្រាវជ្រាវជាមួយភាគីពាក់ព័ន្ធដូចជាគ្រូបង្រៀន និស្សិត និងទីផ្សារការងារ
- បង្កើតកម្មវិធីសិក្សាឯកទេសថ្មីៗ គ្រប់កម្រិតស្របតាមគោលការណ៍និងនីតិវិធីស្តីពី ការអភិវឌ្ឍ កម្មវិធីសិក្សាដោយផ្សារភ្ជាប់ការស្រាវជ្រាវជាមួយភាគីពាក់ព័ន្ធដូចជាគ្រូបង្រៀន និស្សិត និងទីផ្សារការងារ
- ផលសម្រេចរំពឹងទុកនៃកម្មវិធីសិក្សាត្រូវឆ្លើយតបទៅនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ គោលនយោបាយអភិវឌ្ឍជាតិ ពាក់ព័ន្ធយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ ស្តង់ដាជាតិ និងភាគីពាក់ព័ន្ធដូចជាគ្រូបង្រៀន និស្សិត និងទីផ្សារការងារ
- មានរចនាសម្ព័ន្ធនៃកម្មវិធីអប់រំសម្រាប់ឯកទេសនីមួយៗច្បាស់លាស់
- កំណត់ចំនួនក្រេឌីតច្បាស់លាស់លើកម្មវិធីសិក្សាសម្រាប់ឯកទេស សម្រាប់មុខវិជ្ជានីមួយៗ សិក្ខាសាលា សារណា និងនិក្ខេបបទ
- គ្រប់មុខវិជ្ជានៃកម្មវិធីអប់រំមានគម្រោងមុខវិជ្ជាច្បាស់លាស់ដែលបញ្ជាក់អំពី ឈ្មោះគម្រោងមុខវិជ្ជា លេខកូដ មុខវិជ្ជា និងឈ្មោះមុខវិជ្ជា ចំនួនក្រេឌីត មុខវិជ្ជាតម្រូវសិក្សាមុនការពិពណ៌នាមុខវិជ្ជា លទ្ធផលរំពឹងទុកនៃមុខវិជ្ជា ប្លង់មេរៀន វិធីសាស្ត្របង្រៀន រង្វាយតម្លៃការសិក្សា សៀវភៅគោលនិងឯកសារយោង
- ប្លង់មេរៀន ឬផែនការបង្រៀនត្រូវឆ្លើយតបទៅនឹងផលសម្រេចរំពឹងទុកនៃមុខវិជ្ជានីមួយៗ
- មានលទ្ធផលរំពឹងទុកនៃមុខវិជ្ជានីមួយៗដែលឆ្លើយតបទៅនឹងផលសម្រេចរំពឹងទុករបស់កម្មវិធីសិក្សា នៃឯកទេសនីមួយៗ
- កម្មវិធីអប់រំនៃឯកទេសនីមួយៗមានកំណត់អំពីលក្ខខណ្ឌនៃការជ្រើសរើសនិស្សិត និងការបញ្ចប់ការសិក្សា របស់និស្សិតច្បាស់លាស់
- មុខវិជ្ជានីមួយៗនៃកម្មវិធីអប់រំមានសៀវភៅគោល ឬសៀវភៅចងក្រងច្បាស់លាស់ដែលបានសំយោគចេញពីសៀវភៅយោងចំនួនយ៉ាងតិច ៣ ក្បាលផ្សេងគ្នា និង/ឬ ស្នាដៃស្រាវជ្រាវ និង/ឬ កិច្ចការស្រាវជ្រាវ និង/ឬ បទពិសោធការងារជាក់ស្តែង ស្របទៅតាមគម្រោងមុខវិជ្ជា
- មានឯកសារយោងតម្កល់នៅបណ្ណាល័យស្របតាមគម្រោងមុខវិជ្ជា
- មានគោលការណ៍ និងនីតិវិធីស្តីពីការប្រឡងចេញផ្ទៃក្នុង និងថ្នាក់ជាតិសម្រាប់ថ្នាក់បរិញ្ញាបត្រនិងបរិញ្ញាបត្ររងនៃមហាវិទ្យាល័យសុខភាពសាធារណៈ
- បុគ្គលិក គ្រូបង្រៀន និងនិស្សិតបានយល់ច្បាស់អំពីគោលការណ៍ និងនីតិវិធីស្តីពីការសរសេរ និងការការពារសារណា ថ្នាក់បរិញ្ញាបត្រ ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងនីតិវិធីស្តីពីការសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា ថ្នាក់បិរញ្ញាបត្រជាន់ខ្ពស់
- បុគ្គលិក គ្រូបង្រៀន និងនិស្សិតបានយល់ច្បាស់គោលការណ៍ និងនីតិវិធីស្តីពីការបង្រៀនសាកល្បងសម្រាប់ថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ការចុះកម្មសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្ររង និងការចុះកម្មសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្ររងពេទ្យដាច់ទ្បែក
- កម្មវិធីសិក្សានៃឯកទេសនីមួយៗត្រូវបានកំណត់ជាក់លាក់អំពីមុខវិជ្ជា និងចំនួនក្រេឌីតដែលត្រូវចុះកម្មសិក្សា
- កម្មវិធីសិក្សានៃឯកទេសនីមួយៗត្រូវបានកំណត់ពីការការពារសារណា ឬការចុះបង្រៀនសាកល្បង ដើម្បីបញ្ចប់ការសិក្សា

## ១.២.២- ការបង្កើនសមត្ថភាព និងគុណភាពបង្រៀនរបស់គ្រូបង្រៀន/សាស្ត្រាចារ្យ

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- លក្ខន្តិកៈគ្រូបង្រៀនថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ត្រូវបានកែលម្អស្របតាមគោលនយោបាយជាតិ
- ដាក់អនុវត្តសេចក្ដីសម្រេចស្ដីពីការជ្រើសរើស វាយតម្លៃ លើកទឹកចិត្ត អភិវឌ្ឍ និងវិធានការរដ្ឋបាលសម្រាប់គ្រូបង្រៀនថ្នាក់ បរិញ្ញាបត្ររង និងបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់
- ប្រើប្រាស់សេចក្ដីសម្រេចស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់គណៈកម្មការគ្រូបង្រៀតាមឯកទេសថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់
- ប្រកាសសេចក្ដីសម្រេចស្ដីពីឋានៈគ្រូបង្រៀនរបស់សាកលវិទ្យាល័យដល់អ្នកពាក់ព័ន្ធ
- វាយតម្លៃផែនការជ្រើសរើសគ្រូបង្រៀនប្រចាំឆមាស និងប្រចាំឆ្នាំស្របនឹងកម្មវិធីអប់រំ
- មានផលធៀបគ្រូបង្រៀន និងនិស្សិត សម្រាប់មហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នៅអត្រាច្បាស់លាស់សម្រាប់កម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់
- មានអត្រាគ្រូបង្រៀនពេញម៉ោង និងវេលាការសម្រាប់មហាវិទ្យាល័យនីមួយៗច្បាស់លាស់ស្របតាមគោលនយោបាយក្រសួងអប់រំយុវជន និងកីឡា និងក្រសួងសុខាភិបាល
- ជ្រើសរើសគ្រូបង្រៀន ស្របតាមគោលការណ៍ និងនីតិវិធីរបស់សាកលវិទ្យាល័យ
- គ្រូបង្រៀនទទួលបានការអភិវឌ្ឍសមត្ថភាពតាមរយៈការចាត់តាំងឲ្យចូលរួមនៅក្នុងសន្និសីទជាតិ និងអន្តរជាតិ សិក្ខាសាលា និងបទបង្ហាញផ្សេងៗ
- គ្រូបង្រៀនចូលរួមការស្រាវជ្រាវ កិច្ចការរដ្ឋបាល បណ្ដុះបណ្ដាលសហគមន៍ និងសកម្មភាពសង្គម ផ្សេងៗចំនួន ៧០%
- អត្រានៃការបោះបង់ការបង្រៀនរបស់គ្រូបង្រៀនត្រូវបានកំណត់ច្បាស់លាស់

## ១.២.៣- ការអភិវឌ្ឍសម្ភារៈរូបវ័ន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- អនុវត្តបទបញ្ជាផ្ទៃក្នុងស្ដីអំពីការប្រើប្រាស់បន្ទប់សិក្សា និងបន្ទប់អនុវត្តន៍ដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង នៃការសិក្សារបស់និស្សិត
- ផ្សព្វផ្សាយសេចក្ដីណែនាំស្ដីអំពីការប្រើប្រាស់បណ្ណាល័យ
- ផ្សព្វផ្សាយសេចក្ដីណែនាំស្ដីអំពីការស្នាក់នៅអន្តេវាសិកដ្ឋាន
- ផ្សព្វផ្សាយសេចក្ដីណែនាំស្ដីអំពីការប្រើប្រាស់តារាងហ្វូតសាល និងវាយកូនឃ្លីនៅលើតុ
- ផ្សព្វផ្សាយសេចក្ដីណែនាំស្ដីអំពីការប្រើប្រាស់បន្ទប់សោតទស្សន៍
- ផ្សព្វផ្សាយសេចក្ដីណែនាំស្ដីអំពីការប្រើប្រាស់ធនធានរូបវន្តរបស់សាកលវិទ្យាល័យ
- វាយតម្លៃផែនការអភិវឌ្ឍធនធានរូបវន្តរយៈពេលខ្លី និងរយៈពេលវែងដើម្បីគាំទ្រដល់ការបង្រៀន និងសិក្សាស្រាវជ្រាវ
- បន្ទប់សិក្សាគ្រប់គ្រាន់ មានបំពាក់សម្ភារៈសិក្សាដូចជា តុ កៅអី ក្ដាឃៀន វាំងនន LCD Screen
- បន្ទប់សិក្សាអនុវត្ត គ្រប់គ្រាន់ មានបំពាក់សម្ភារៈសិក្សាដូចជា តុ កៅអី ក្ដាឃៀន វាំងនន កុំព្យូទ័រ LCD, Screen
- បន្ទប់សិក្សាអនុវត្តគ្រាប់មានបំពាក់សម្ភារៈឆ្លើយតបតាមការកំណត់របស់ក្រសួងសុខាភិបាល
- សាលប្រជុំមានសម្ភារៈបរិក្ខាគ្រប់គ្រាន់ និងទំនើបដូចជា LCD, Screen, Speakers, Multiplexer

- បន្ទប់ពិសោធន៍សម្រាប់និស្សិតពេទ្យ កសិកម្ម វិស្វកម្ម សំណង់និងស្ថាបត្យកម្មឆ្លើយតបនឹងស្តង់ដារអប់រំជាតិ
- មានបន្ទប់អនុវត្តន៍សវនាការ សម្រាប់និស្សិតនីតិសាស្ត្រ
- ប្រើប្រាស់បន្ទប់សណ្ឋាគារលំដាប់ផ្កាយប្រាំគំរូ សម្រាប់និស្សិតឯកទេសគ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ ហាត់ការជាក់ស្តែង
- មានបន្ទប់អនុវត្តន៍កុំព្យូទ័រទំនើប
- មានបន្ទប់ Multi-Media សម្រាប់បង្ហោះស្នាដៃដែលបង្កើតថ្មីៗ
- មានបន្ទប់ប្រឡងភាសាបរទេសស្របតាមស្តង់ដារច្បាស់លាស់
- មានបណ្ណាល័យដែលមានកន្លែងអានគ្រប់គ្រាន់ មានអំណោយផលដល់ការសិក្សា និងស្រាវជ្រាវ
- សម្ភារៈបរិក្ខាគ្រប់គ្រាន់ដូចជា កុំព្យូទ័រ សៀវភៅគោល សៀវភៅយោង ទស្សនាវដ្តីវិទ្យាសាស្ត្រ និងសម្ភារៈសិក្សា ផ្សេងៗ សម្រាប់គាំទ្រដល់កម្មវិធីសិក្សាអប់រំ
- មានសេវា Internet គ្រប់គ្រាន់ទាំងមានខ្សែ និងគ្មានខ្សែដើម្បីគាំទ្រដល់ ការបង្រៀន ការសិក្សា និងការស្រាវជ្រាវ
- មានកាមេរ៉ាសុវត្ថិភាព ដើម្បីការពារសន្តិសុខ និងសុវត្ថិភាព
- ផ្សព្វផ្សាយសេចក្តីណែនាំស្តីអំពីសុខភាព សុវត្ថិភាព និសន្តិសុខ សម្រាប់បុគ្គលិក គ្រូបង្រៀន និងសាធារណៈជន
- សម្ភារៈរូបវន្តសម្រាប់ពន្លត់អគ្គីភ័យ ប្រអប់សង្គ្រោះបន្ទាន់ត្រូវបានបំពាក់គ្រប់គ្រាន់
- មានទីធ្លា តារាងបាល់ទាត់ហ្វូតសាល កន្លែងវាយកូនឃ្លីលើតុ និងសម្ភារៈកីឡាសម្រាប់បុគ្គលិក គ្រូបង្រៀន និងនិស្សិត
- មានអាហារដ្ឋានសម្រាប់បុគ្គលិក គ្រូបង្រៀន និងនិស្សិតប្រកបដោយផាសុកភាព និងគុណភាព និងតម្លៃសមរម្យ
- ផ្សព្វផ្សាយសេចក្តីណែនាំស្តីអំពីការថែរក្សាការពារ ទិន្នន័យ និងសម្ភារៈអេឡិចត្រូនិកសាកលវិទ្យាល័យជាសាធារណៈ
- មានបន្ទប់សង្គ្រោះបឋម និង/ឬប្រអប់ថ្នាំសង្គ្រោះបឋមដែលមានសម្ភារៈបរិក្ខារគ្រប់គ្រាន់ស្របតាមស្តង់ដារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ១.២.៤- ការលើកកម្ពស់គុណភាពសិក្សា និងស្រាវជ្រាវ

## ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុងស្តីពីដំណើរការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់
- អនុវត្តសេចក្តីសម្រេចស្តីពីការជ្រើសរើសនិស្សិតចុះឈ្មោះចូលរៀន ប្រឡងបញ្ចប់ការសិក្សា និង/ឬការការពារនិក្ខេបបទតាមកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់យ៉ាងមានប្រសិទ្ធភាពខ្ពស់
- មានផែនការម៉ាឃីតធីងទាក់ទាញនិស្សិតថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ តាមឯកទេស និងកម្រិតសិក្សា
- និស្សិតចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់កើនឡើងចំនួន ២០% រៀងរាល់ឆ្នាំ
- ក្រុមប្រឹក្សាធានាគុណភាពអប់រំគ្រប់ថ្នាក់សិក្សាដំណើរការស្របតាមតួនាទីនិងភារកិច្ចដែលកំណត់ដោយសេចក្តីសម្រេចស្តីពីក្រុមប្រឹក្សាធានាគុណភាពអប់រំមូលដ្ឋានរបស់សាកលវិទ្យាល័យ
- អត្រានិស្សិតចូលរួមក្នុងកម្មវិធី Extra Curricular ដូចជា សន្និសីទ សិក្ខាសាលា ការសិក្សាក្រៅថ្នាក់ និងបទបាឋកថាផ្សេងៗចំនួន ៩៥ ភាគរយ
- វាគ្មិនល្បីៗដែលគុណវុឌ្ឍិ និងបទពិសោធការងារយូរឆ្នាំ ដើម្បីធ្វើសន្និសីទ សិក្ខាសាលា និងបាឋកថា តាមឯកទេសនីមួយៗ ចំនួន ១ ដងក្នុងមួយឆមាស
- និស្សិតចំនួន ៩៥% ចូលរួមការស្រាវជ្រាវ កិច្ចការរដ្ឋបាល បណ្តុះបណ្តាលសហគមន៍ និងសកម្មភាពសង្គមផ្សេងៗ

- មាននិស្សិតបោះបង់ការសិក្សាពីចាប់ផ្តើមរហូតដល់បញ្ចប់ការសិក្សាលើកលែងមហាវិទ្យាល័យសុខភាពសាធារណៈដូចជា ថ្នាក់បរិញ្ញាបត្ររង ចំនួន ១៥% ថ្នាក់បរិញ្ញាបត្រ ចំនួន ២០% និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន ១៥%
- និស្សិតមហាវិទ្យាល័យសុខភាពសាធារណៈឯកទេសគិលានុប្បដ្ឋាក និងឆ្មប បោះបង់ការសិក្សាពីចាប់ផ្តើមរហូតដល់បញ្ចប់ការសិក្សាដូចជា ថ្នាក់បរិញ្ញាបត្ររង ចំនួន ៥% និងថ្នាក់បរិញ្ញាបត្រ ចំនួន ១០%
- និស្សិតមហាវិទ្យាល័យសុខភាពសាធារណៈឯកទេសឱសថ បោះបង់ការសិក្សាពីចាប់ផ្តើមរហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ចំនួន ១០%
- ទិន្នន័យ និងព័ត៌មានរបស់និស្សិតចុះឈ្មោះចូលរៀន និស្សិតកំពុងសិក្សា និងនិស្សិតបញ្ចប់ការសិក្សាត្រូវបានគ្រប់គ្រង និងរក្សាទុកប្រកបយ៉ាងច្បាស់លាស់ និងសុវត្ថិភាព។

## ១.២.៥- ការបង្កើនគុណភាពនៃការផ្តល់សេវាកម្មដល់និស្សិត

## ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ប្រជុំនិស្សិតប្រចាំឆមាសចំនួន ១ ដង ស្តីពីការសំណូមពរ និងដំណោះស្រាយបញ្ហាទាក់ទងនឹងការសិក្សា
- ជួបនិស្សិតតាមថ្នាក់រៀនប្រចាំឆមាសចំនួន ១ ដង ស្តីពីការសំណូមពរនិងដំណោះស្រាយ បញ្ហាទាក់ទង នឹង ការសិក្សារបស់និស្សិត
- និស្សិតគ្រប់កម្រិតសិក្សាចំនួន ១០០%ទទួលបានការប្រឹក្សាពេលអវត្តមានចំនួន ៨ដង
- និស្សិតរៀនខ្សោយ ទទួលបានការប្រឹក្សាពីបុគ្គលិក ឬគ្រូបង្រៀននៃមុខវិជ្ជានីមួយៗ ចំនួន ១០០%
- និស្សិតគ្រប់កម្រិតសិក្សាអាចទទួលបានការប្រឹក្សាអំពីបញ្ហាផ្ទាល់ខ្លួន ដូចជា សេដ្ឋកិច្ចគ្រួសារ ការងារ សុខភាព និងច្បាប់ ។ល។
- និស្សិតធ្វើការផ្លាស់ប្តូរការសិក្សាជាមួយសាកលវិទ្យាល័យដៃគូក្រៅប្រទេស ចំនួន ១០%
- មាននិស្សិតទទួលបានអាហារូបករណ៍ក្រៅប្រទេសចំនួន ២%
- បេក្ខជនចំនួន ១០% ចូលរួមប្រឡងយកអាហារូបករណ៍ទៅសិក្សានៅបរទេស ដែលរៀបចំដោយសាកលវិទ្យាល័យដៃគូ ឬដៃគូអភិវឌ្ឍន៍នានា
- និស្សិតកំពុងសិក្សាមានការងារធ្វើ ដូចជា និស្សិតឆ្នាំទី ១ ចំនួន ១៥% និស្សិតឆ្នាំទី ២ ចំនួន ៣៥% និស្សិតឆ្នាំទី ៣ ចំនួន ៦០% និស្សិតឆ្នាំទី ៤ ចំនួន ៨០% និងនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើចំនួន ៩៥%
- និស្សិតបញ្ចប់ការសិក្សាមានការងារធ្វើស្របតាមឯកទេស ចំនួន ៦៥%
- រៀបចំពិធីចែកសញ្ញាបត្រដល់និស្សិតជ័យលាភីគ្រប់ជំនាន់
- និស្សិតជ័យលាភីចូលរួមទទួលសញ្ញាបត្រចំនួន ៩៥ %
- ផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រុមនិស្សិតស្ម័គ្រចិត្តសាកលវិទ្យាល័យ
- បោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានក្រុមនិស្សិតស្ម័គ្រតាមអាណត្តិច្បាស់លាស់
- ក្រុមនិស្សិតស្ម័គ្ររៀបចំព្រឹត្តិការណ៍ ឬកម្មវិធីផ្សេងៗ យ៉ាងតិចចំនួន ២ ដងក្នុងមួយឆ្នាំ
- មានសេចក្តីសម្រេចស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់សមាគមន៍អតីតនិស្សិត
- បោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានសមាគមន៍អតីតនិស្សិតតាមអាណត្តិច្បាស់លាស់
- សមាគមន៍អតីតនិស្សិតរៀបចំព្រឹត្តិការណ៍ ឬកម្មវិធីផ្សេងៗ យ៉ាងតិចចំនួន ១ ដងក្នុងមួយឆ្នាំ
- បោះដំរុំផ្លាស់ប្តូរវប្បធម៌ជាមួយនិស្សិតជាតិ និងអន្តរជាតិ នៅក្នុងនិងក្រៅប្រទេស ចំនួន ២ ដងក្នុងមួយឆ្នាំ។

## ១.៣- ការស្រាវជ្រាវ និងការអភិវឌ្ឍ

ការស្រាវជ្រាវដើរតួទីយ៉ាងសំខាន់ដើម្បីធ្វើឲ្យការបង្រៀនប្រកបដោយភាពជោគជ័យ អភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន និងជំនួយដល់ការសិក្សារបស់និស្សិតគ្រប់ម្រិតជាពិសេសនៅកម្រិតឧត្តមសិក្សា។ ដូចនេះ ដើម្បីជំរុញ សាស្ត្រាចារ្យ បុគ្គលិក និស្សិត ឲ្យមានវប្បធម៌ស្រាវជ្រាវ សាកលវិទ្យាល័យ អង្គរ បានកំណត់យុទ្ធសាស្ត្រសំខាន់ៗចំនួន ០៥ ដូចខាងក្រោមៈ

1) ការរៀបចំការស្រាវជ្រាវសម្រាប់អភិវឌ្ឍសាកលវិទ្យាល័យ
2) ការបង្កើតវប្បធម៌ស្រាវជ្រាវ និងអំណានរបស់និស្សិត
3) ការបង្កើតវប្បធម៌ស្រាវជ្រាវរបស់បុគ្គលិក និងគ្រូបង្រៀន/សាស្ត្រាចារ្យ
4) ការធ្វើទំនើបកម្ម និងនវានុវត្តភាពឯកសារសម្រាប់ស្រាវជ្រាវ
5) ការបោះពុម្ព និងផ្សព្វផ្សាយ ។

### ១.៣.១-ការរៀបចំការស្រាវជ្រាវសម្រាប់អភិវឌ្ឍសាកលវិទ្យាល័យ

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ផ្សព្វផ្សាយគោលនយោបាយស្រាវជ្រាវដែលជាមាគ៌ាសម្រាប់អភិវឌ្ឍ និងបេកគំហើញប្រកបដោយចិរភាព
- រចនាសម្ព័ន្ធស្រាវជ្រាវស្របតាមបេសកកម្ម គោលដៅ និងផែនការស្រាវជ្រាវរបស់សាកលវិទ្យាល័យ ព្រមទាំងមានកំណែទម្រង់ស្របតាមការចំបាច់
- កំណត់តួនាទីភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់របស់បុគ្គលិកស្រាវជ្រាវ និងគណៈកម្មការស្រាវជ្រាវ
- មានលិខិតបទដ្ឋានតែងតាំងមន្ត្រី និងគណៈកម្មការស្រាវជ្រាវច្បាស់លាស់
- អ្នកស្រាវជ្រាវប្រកបដោយឆន្ទៈ និងមានការទទួលខុសត្រូវខ្ពស់
- អ្នកស្រាវជ្រាវមានគុណវឌ្ឍិចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ ដែលមានបទពិសោធ ឆ្លើយតបតាមរចនាសម្ព័ន្ធស្រាវជ្រាវ
- មានគណៈកម្មការស្រាវជ្រាវច្បាស់លាស់ ដែលមានគុណវឌ្ឍិចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ និងមានបទពិសោធឆ្លើយតបទៅនឹងគម្រោងស្រាវជ្រាវនីមួយៗ
- ពិនិត្យនិងវាយតម្លៃផែនការអភិវឌ្ឍសមត្ថភាពអ្នកស្រាវជ្រាវប្រចាំឆ្នាំ ឱ្យបានច្បាស់លាស់ដែលធានានិរន្តរភាពស្ថាប័ន
- ទាក់ទាញគម្រោងមូលនិធិស្រាវជ្រាវយ៉ាងតិចមួយជារៀងរាល់ឆ្នាំពីអង្គភាពរដ្ឋ និងមិនមែនរដ្ឋាភិបាល

### ១.៣.២-ការបង្កើតវប្បធម៌ស្រាវជ្រាវ និងអំណានរបស់និស្សិត

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- គណកម្មការរៀបចំកម្មវិធីប្រកួតប្រជែងអំណានរបស់សាកលវិទ្យាល័យ ប្រចាំឆ្នាំជាភាសាជាតិ និងអន្តរជាតិមុនពេលរៀបចំ ព្រឹត្តិការណ៍ម្តងៗ
- បង្កើតកម្មវិធីប្រកួតប្រជែងអំណានរបស់សាកលវិទ្យាល័យ ប្រចាំឆ្នាំជាភាសាជាតិ និងអន្តរជាតិដែលមានផែនការច្បាស់លាស់
- មានគណៈកម្មការសម្រាប់រៀបចំវេទិកាស្នាដៃនិស្សិតរបស់សាកលវិទ្យាល័យ
- ផ្តល់បណ្ណសរសើរ ឬរង្វាន់ឬពិន្ទុសម្រាប់ការស្រាវជ្រាវរបស់និស្សិតផ្អែកតាមលក្ខណៈវិនិច្ឆ័យច្បាស់លាស់។

### ១.៣.៣- ការបង្កើតវប្បធម៌ស្រាវជ្រាវរបស់បុគ្គលិក និងគ្រូបង្រៀន/សាស្ត្រាចារ្យ

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ស្រាវជ្រាវអំពីលទ្ធផលសិក្សារបស់និស្សិតបញ្ចប់ការសិក្សា(Tracer Study)ប្រចាំឆ្នាំ គ្រប់កម្រិត និងគ្រប់ឯកទេសដើម្បីអភិវឌ្ឍកម្មវិធីសិក្សា
- ស្រាវជ្រាវអំពីវិធីសាស្ត្រសិក្សា និងបង្រៀនបែបទំនើប ស្របតាមបរិបទអប់រំ អន្តរជាតិប្រចាំឆ្នាំ ដោយមានកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និង ឬ អន្តរជាតិដើម្បីពង្រឹង/គុណភាពសិក្សា និងបង្រៀន
- ស្រាវជ្រាវអំពីតម្រូវការទីផ្សារការងារប្រចាំឆ្នាំ ដើម្បីអភិវឌ្ឍកម្មវិធីសិក្សា
- ផ្សព្វផ្សាយគោលនយោបាយការពារស្នាដៃរបស់អ្នកស្រាវជ្រាវ ស្របតាមស្តង់ដាជាតិ និងអន្តរជាតិ។

### ១.៣.៤- ការធ្វើទំនើបកម្ម និងនវានុវត្តភាពឯកសារសម្រាប់ស្រាវជ្រាវ

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ផ្តល់ឱកាសឲ្យអ្នកស្រាវជ្រាវចូលរួមសិក្ខាសាលាជាតិ អន្តរជាតិ និងវគ្គសិក្សាពាក់ព័ន្ធការស្រាវជ្រាវបែបទំនើប
- មានអត្ថបទស្រាវជ្រាវថ្មីៗកើនឡើង៥ ភាគរយជារៀងរាល់ឆ្នាំ
- មានអត្ថបទស្រាវជ្រាវជាឌីជីថល ១០០ ភាគរយ។

### ១.៣.៥- ការបោះពុម្ព និងផ្សព្វផ្សាយ

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- គណៈកម្មការបោះពុម្ព និងផ្សព្វផ្សាយគោរពតួនាទីភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់
- ផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវគ្រប់គម្រោងស្រាវជ្រាវឲ្យបានទូលំទូលាយ ដូចជាការរៀបចំសិក្ខាសាលា សន្និសីទ របាយការណ៍/ព្រឹត្តិបត្រ គេហទំព័រ Facebook និង បណ្ណាល័យសាកលវិទ្យាល័យ អង្គរ។

## ១.៤- ការទំនាក់ទំនង និងសហប្រតិបត្តិការអន្តរជាតិ

ដើម្បីសម្រេចតាមបានចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់ ដៃគូទំនាក់ទំនងអន្តរជាតិពិតជាចាំបាច់ណាស់សម្រាប់ជួយដល់ការបង្កើតនូវស្តង់ដារមួយធានាអោយមានការផ្លាស់ប្តូរវប្បធម៌ ការពង្រីកចំណេះដឹង និងចំណេះធ្វើដែលជាមូល ដ្ឋានដ៏រឹងមាំនៅក្នុងឆាកអន្តរជាតិ ។ ជាងនេះទៅទៀតការបង្កើនដៃគូសហប្រតិបត្តិការអន្តរជាតិនឹងជួយសម្របសម្រួលដល់ការផ្លាស់ប្តូរបុគ្គលិក សាស្ត្រាចារ្យ និងនិស្សិត ដើម្បីធានាការបង្កើនធនធានមនុស្សប្រកបទៅដោយគុណភាព និងភាពជាអ្នកដឹកនាំក្នុងបរិបទសាកលភាវូបនីយកម្ម។ ហេតុដូចនេះ សាកលវិទ្យាល័យ អង្គរ បានកំណត់ទិសដៅយុទ្ធសាស្ត្រ សំខាន់ៗចំនួន ០៤ ដូចខាងក្រោម ៖

1) ការពង្រឹង និងពង្រីកភាពជាដៃគូសហប្រតិបត្តិការ
2) ការផ្លាស់ប្តូរវប្បធម៌
3) ការផ្តល់អាហាររូបករណ៍
4) ការស្រាវជ្រាវរួមគ្នា។

### ១.៤.១- ការពង្រឹង និងពង្រីកភាពជាដៃគូសហប្រតិបត្តិការ

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ស្ថាប័នអប់រំអន្តរជាតិ ក្រុមហ៊ុនអន្តរជាតិដទៃៗផ្សេងទៀតក្លាយជាដៃគូសម្រាប់ផ្លាស់ប្តូរបទពិសោធគ្រប់គ្រង បង្រៀន សិក្សា និងអនុវត្ត

- អនុវត្ត MOU និង MOA ជាមួយដៃគូសហប្រតិបត្តិការអន្តរជាតិ ដែលមានស្រាប់យ៉ាងសកម្ម
- ចុះ MOU និង ឬ/MOA ថ្មីៗ ជាមួយដៃគូសហប្រតិបត្តិការគ្រឹះស្ថានឧត្តមសិក្សា និង/ឬដៃគូពាក់ព័ន្ធនៅសហគមន៍អាស៊ាន

## ១.៤.២- ការផ្លាស់ប្តូរវប្បធម៌

## ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- វាយតម្លៃផែនការទស្សនកិច្ចសិក្សា សម្រាប់បុគ្គលិក គ្រូបង្រៀន និងនិស្សិតគ្រប់កម្រិតសិក្សា ដើម្បីទស្សនកិច្ចសិក្សាគ្រឹះស្ថានសិក្សា និងរម្យណីយដ្ឋាននានាក្នុង និងក្រៅប្រទេស សំដៅសិក្សាស្វែងយល់ និងធានានិរន្តរស្ថាប័ន
- ធ្វើទស្សនកិច្ចសិក្សាក្រៅប្រទេសចំនួន ២ ដងនៃឆ្នាំសិក្សានីមួយៗ ដែលមានការចូលរួមពីបុគ្គលិក គ្រូបង្រៀន និងនិស្សិតគ្រប់កម្រិត
- ធ្វើទស្សនកិច្ចសិក្សាក្នុងប្រទេសចំនួន ៣ ដងនៃឆ្នាំសិក្សានីមួយៗ ដែលមានការចូលរួមពីបុគ្គលិក គ្រូបង្រៀន និងនិស្សិតនៃសាកលវិទ្យាល័យដៃគូ

## ១.៤.៣- ការផ្តល់អាហាររូបករណ៍

## ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ផ្សព្វផ្សាយគោលការណ៍សម្រាប់និស្សិតអាហាររូបករណ៍សិក្សានៅសាកលវិទ្យាល័យ អង្គរ ដែលតម្រូវឲ្យនិស្សិតអាហារូបករណ៍បម្រើការងារយ៉ាងតិច ៦០ម៉ោង ក្នុង១ឆ្នាំ និស្សិតអាហារូបករណ៍ ៥០% បម្រើការងារយ៉ាងតិច ៣០ម៉ោង ក្នុង១ឆ្នាំ និងនិស្សិតអាហារូបករណ៍ ២៥% បម្រើការងារយ៉ាងតិច ១៥ម៉ោង ក្នុង១ឆ្នាំ។
- លើកទឹកចិត្តជាអាហារូបករណ៍សិក្សានៅសាកលវិទ្យាល័យ អង្គរ ដល់និស្សិតឆ្នើមតាមជំនាន់
- វាយតម្លៃផែនការផ្តល់អាហាររូបករណ៍សម្រាប់បុគ្គលិក សាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យអង្គរសិក្សានៅសាកលវិទ្យាល័យដៃគូ និងសាកលវិទ្យាល័យនៅលើពិភពលោកនៃឆ្នាំសិក្សានីមួយៗច្បាស់លាស់
- និស្សិតគ្រប់កម្រិតទទួលបានអាហាររូបករណ៍សិក្សានៅសាកលវិទ្យាល័យដៃគូចំនួន ១០ នាក់នៃឆ្នាំសិក្សានីមួយៗ
- បង្កើតយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការសិក្សានិស្សិតអាហាររូបករណ៍ច្បាស់លាស់
- មានការពេញចិត្តពីសាកលវិទ្យាល័យដៃគូចំពោះការសិក្សា និងឥរិយាបថរបស់និស្សិតអាហាររូបករណ៍
- និស្សិតអាហាររូបករណ៍ ១០០% ដែលបានបញ្ចប់ការសិក្សាចូលរួមអភិវឌ្ឍសាកលវិទ្យាល័យ និងសង្គមជាតិ

## ១.៤.៤- ការស្រាវជ្រាវរួមគ្នា

## ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ផ្សព្វផ្សាយគោលការណ៍វិធីស្តីពីការស្រាវជ្រាវរួមគ្នាដែលកំណត់ពីក្រមសីលធម៌វិជ្ជាជីវៈស្របតាមបេសកកម្ម និងគោលដៅរបស់សាកលវិទ្យាល័យ
- វាយតម្លៃផែនការស្រាវជ្រាវរួមគ្នាប្រចាំឆ្នាំនិងផែនការសកម្មភាពប្រចាំខែសម្រាប់ដំណើរការស្រាវជ្រាវរួមគ្នាច្បាស់លាស់
- មានផែនការថវិកាសម្រាប់គាំទ្រការស្រាវជ្រាវរួមគ្នាច្បាស់លាស់

## ១.៥- ការទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ និងអន្តរជាតិ

យន្តការ នៃការធានាគុណភាពអប់រំនឹងជាចលករដ៏សំខាន់សម្រាប់អភិវឌ្ឍសកម្មភាពការគ្រប់គ្រង ការបង្រៀន និការសិក្សាធានាគុណភាព អប់រំឧត្តមសិក្សា ដើម្បីផលិតចេញនូវធនធានមនុស្សប្រកប ដោយគុណភាព និងលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់អភិវឌ្ឍប្រទេសជាតិ លើគ្រប់វិស័យ។ ដូច្នេះដើម្បីធានាគុណភាពអប់រំស្រេបតាមស្តង់ដារជាតិ និអន្តរជាតិ សាកលវិទ្យាល័យ អង្គរ បានកំណត់ទិសដៅយុទ្ធសាស្ត្រសំខាន់ៗចំនួន ០៤ ដូចខាងក្រោមៈ

1) ការរៀបចំប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង
2) ដំណើរការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង
3) ការវាយតម្លៃគុណភាពអប់រំថ្នាក់ជាតិ
4) ការវាយតម្លៃគុណភាពអប់រំថ្នាក់អន្តរជាតិ

### ១.៥.១- ការរៀបចំប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- មានស្តង់ដារសម្រាប់វាយតម្លៃគុណភាពអប់រំផ្ទៃក្នុងស្របតាមស្តង់ដារជាតិ
- ផ្សព្វផ្សាយគោលការណ៍ និងនីតិវិធីសម្រាប់វាយតម្លៃគុណភាពអប់រំច្បាស់លាស់
- មានសៀវភៅណែនាំ និងឧបករណ៍សម្រាប់ដំណើការវាយតម្លៃគុណភាពអប់រំច្បាស់លាស់
- បង្កើតសិក្ខាសាលាពិគ្រោះយោបល់កែលម្អស្តង់ដារ សៀវភៅណែនាំ គោលការណ៍ និងនីតិវិធីវាយតម្លៃគុណភាពផ្ទៃក្នុង
- បង្កើតរចនាសម្ព័ន្ធគ្រប់គ្រងការធានាគុណភាពអប់រំផ្ទៃក្នុង ដែលមានគុណវុឌ្ឍិ និងបទពិសោធន៍សមស្រប ព្រមទាំងបានកំណត់តួនាទី ភារកិច្ចនិងការទទួលខុសត្រូវច្បាស់លាស់ ដូចជាដេប៉ាតឺម៉ង់ធានាគុណភាពផ្ទៃក្នុង គណៈកម្មការធានាគុណភាពអប់រមផ្ទៃក្នុង និងក្រុមមន្ត្រីវាយតម្លៃគុណភាពអបរំផ្ទៃក្នុងជាដើម
- ចំនួនមន្ត្រីសមស្របតាមរចនាសម្ព័ន្ធគ្រប់គ្រង ដែលធានាគុណភាព និងនិរន្តរភាព
- ផ្សព្វផ្សាយនិងបណ្តុះបណ្តាលប្រព័ន្ធធានាគុណភាពដល់អ្នកពាក់ព័ន្ធឲ្យបានទូលំទូលាយនិងមានប្រសិទ្ធភាព
- វាយតម្លៃផែនការអភិវឌ្ឍសមត្ថភាពមន្ត្រី ក្រុមមន្ត្រីវាយតម្លៃ និងគណៈកម្មការធានាគុណភាពអប់រំច្បាស់លាស់

### ១.៥.២- ដំណើរការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង

### ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- បង្កើតផែនការសកម្មភាពវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងជាក់លាក់
- មានធនធានហិរញ្ញវត្ថុនិងធនធានសម្ភារៈគ្រប់គ្រាន់សម្រាប់វាយតម្លៃគុណភាពអប់រំផ្ទៃក្នុងច្បាស់លាស់
- ផ្សព្វផ្សាយផែនការសកម្មភាព និងកម្មវិធីវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងដល់អ្នកពាក់ព័ន្ធ
- ធ្វើការស្វ័យវាយតម្លៃគុណភាពអប់រំរបស់អង្គភាពចំណុះ និងរបាយការណ៍ស្វ័យវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង
- វាយតម្លៃគុណភាពអប់រំផ្ទៃក្នុងស្របតាមស្តង់ដា គោលការណ៍ នីតិវិធី និងផែនការ
- គាំទ្រ និងសហការចូលរួមពីអង្គភាពចំណុះ និងអ្នកពាក់ព័ន្ធសមស្រប
- មានរបាយការណ៍លទ្ធផលនៃការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងច្បាស់លាស់ និងបានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ
- កែលម្អ ផែនការសកម្មភាពដោយផ្អែកតាមអនុសាសន៍របស់ក្រុមមន្ត្រីវាយតម្លៃ
- ធ្វើការស្វ័យវាយតម្លៃគុណភាពអប់រំនៅសាកលវិទ្យាល័យ អង្គរ ជាទម្លាប់។

## ១.៥.៣- ការវាយតម្លៃគុណភាពអប់រំថ្នាក់ជាតិ

## ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ទទួលបានការស្គាល់គុណភាពអប់រំពេញសិទ្ធិពី គណៈកម្មការវាយតម្លៃគុណភាពអប់រំកម្ពុជា ( គទក ឬACC )
- ផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃគុណភាពអប់រំ របស់គទក ដល់អ្នកពាក់ព័ន្ធទូលំទូលាយ
- កែលម្អតាមអនុសាសន៍របស់ក្រុមមន្ត្រីវាយតម្លៃប្រកបដោយប្រសិទ្ធភាពខ្ពស់
- លើកទឹកចិត្តបុគ្គលិកពាក់ព័ន្ធដែលមានស្នាដៃ។

## ១.៥.៤- ការវាយតម្លៃគុណភាពអប់រំថ្នាក់អន្តរជាតិ

## ក. លទ្ធផលរំពឹងទុកនៃទិសដៅយុទ្ធសាស្ត្រ

- ទទួលបានការស្គាល់គុណភាពអប់រំពេញសិទ្ធិពី គណៈកម្មការវាយតម្លៃគុណភាពអប់រំអន្តរជាតិ
- ផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃគុណភាពអប់រំរបស់ស្ថាប័នអន្តរជាតិដល់អ្នកពាក់ព័ន្ធទូលំទូលាយ
- កែលម្អដោយបញ្ចូលអនុសាសន៍របស់ក្រុមមន្ត្រីវាយតម្លៃទៅក្នុងផែនការ
- កែលម្អតាមអនុសាសន៍របស់ក្រុមមន្ត្រីវាយតម្លៃប្រកបដោយប្រសិទ្ធភាពខ្ពស់
- លើកទឹកចិត្តបុគ្គលិកពាក់ព័ន្ធដែលមានស្នាដៃ។

**ជំពូក ៤**

# ផែនការសកម្មភាព

**១. ការពង្រឹងការគ្រប់គ្រងប្រកបដោយភាពជាអ្នកដឹកនាំ**

| ទិសដៅយុទ្ធសាស្ត្រ | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | កាលបរិច្ឆេទ | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | អេឃ្យូ | ដៃគូ |
| ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចច្បាស់លាស់ | - មានប្រព័ន្ធគ្រប់គ្រងរួម និងដោយឡែក ដែលបញ្ជាក់ពីសិទ្ធអំណាច និងលំហូរការងារច្បាស់លាស់ ឆ្លើយតបទៅ នឹងចក្ខុវិស័យ បេសកកម្ម និងគោលបំណងរបស់សាកលវិទ្យាល័យ ព្រមទាំងធានាប្រសិទ្ធភាព នៃការគ្រប់គ្រង និងនិរន្តរភាពស្ថាប័ន | រៀបចំ និងគ្រប់គ្រង | ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | - ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាបណ្ដុះបណ្ដាល គណៈកម្មការនានា មានចំនួន ស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងរួម និងដោយឡែករបស់សាកលវិទ្យាល័យ | រៀបចំ អនុម័ត និងផ្សព្វផ្សាយ សម្រាប់អនុវត្ត | ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង | ✓ | ✓ | | | | ✓ | |
| | - កំណត់ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាបណ្ដុះបណ្ដាល គណៈកម្មការនានា ថ្នាក់ដឹកនាំ បុគ្គលិក ស្របតាមរចនាសម្ព័ន្ធគ្រប់គ្រង និងគាំទ្រផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ | រៀបចំ អនុម័ត និងផ្សព្វផ្សាយ សម្រាប់អនុវត្ត | ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង | ✓ | | | | | ✓ | |

| | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | ខ្លី | វែង |
|---|---|---|---|---|---|---|---|---|---|---|
| | -ធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិក ឆ្លើយតបទៅនឹងគោលនយោបាយជាតិ និងបរិបទអប់រំអាស៊ាន ហើយជានាប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រង និងប្រតិបត្តិការរបស់ក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ | វិភាគ និងកែលម្អ | ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង | ✓ | | | | | ✓ | |
| | -ធ្វើវិសោធនកម្មគោលនយោបាយ ឬ គោលការណ៍និងនីតិវិធីស្តីពីការជ្រើសរើស វាយតម្លៃ លើកទឹកចិត្ត និងអភិវឌ្ឍបុគ្គលិក និងក្រុមប្រឹក្សាភិបាល ឆ្លើយតបទៅនឹងគោលនយោបាយជាតិ បរិបទអប់រំ និងទីផ្សារការងារអាស៊ាន ដែលមានតម្លាភាព គុណភាព ប្រសិទ្ធភាពខ្ពស់ និងធានានិរន្តរភាពស្ថាប័ន | វិភាគ និងកែលម្អ | ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង | ✓ | | | | | ✓ | |
| | - គោលការណ៍ នីតិវិធី និងទម្រង់បែបបទផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពរយៈពេល ០៥ ឆ្នាំ ផែនការសកម្មភាពប្រចាំឆ្នាំ និងប្រចាំខែ ស្របតាមគោលនយោបាយជាតិ និងអន្តរជាតិ | រៀបចំ អនុម័ត និងផ្សព្វផ្សាយ សម្រាប់អនុវត្ត | ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង | ✓ | | | | | ✓ | |

| | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ២៨-២៩ | ២៩-៣០ | ៣០-៣១ | ៣១-៣២ | ៣២-៣៣ | បន្ត | ថ្មី |
|---|---|---|---|---|---|---|---|---|---|---|
| | - មានផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពរយៈពេល ០៥ឆ្នាំ ផែនការសកម្មភាពប្រចាំឆ្នាំ និងខែច្បាស់លាស់ស្របតាមគោលការណ៍ នីតិវិធី និងទម្រង់បែបបទរបស់សាកលវិទ្យាល័យ ហើយត្រូវបានស្ថាប័ន អង្គភាពចំណុះ និងអ្នកពាក់ព័ន្ធចូលរួមពិគ្រោះយោបល់ ព្រមទាំងយល់ដឹងទូលំទូលាយ ។ | រៀបចំ អនុម័ត និង ផ្សព្វផ្សាយ សម្រាប់អនុវត្ត | ក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រង | ✓ | | | | | ✓ | |
| ការលើកកម្ពស់សមត្ថភាពបុគ្គលិក និងការលើកទឹកចិត្ត | - ធ្វើការជ្រើសរើស វាយតម្លៃ លើកទឹកចិត្ត និងអភិវឌ្ឍបុគ្គលិក និងក្រុមប្រឹក្សាភិបាល ស្របតាមគោលការណ៍ និងនិតិវិធីរបស់សាកលវិទ្យាល័យ | ផ្សព្វផ្សាយ សម្ភាស វាយតម្លៃ និងបណ្តុះបណ្តាល | ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងការិ. រដ្ឋបាល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | -ក្រុមប្រឹក្សាភិបាលមានសញ្ញាបត្របណ្ឌិតយ៉ាងតិចចំនួន ៥០ ភាគរយ បរិញ្ញាបត្រជាន់ខ្ពស់ ៣០ ភាគរយ និងបរិញ្ញាបត្រ ២០ ភាគរយនៃចំនួនសរុប | ផ្សព្វផ្សាយ សម្ភាស វាយតម្លៃ និងបណ្តុះបណ្តាល | ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងការិ. រដ្ឋបាល | ✓ | | | | | ✓ | |
| | - អ្នកគ្រប់គ្រងថ្នាក់កំពូលមានសញ្ញាបត្របណ្ឌិតចំនួន ៧០% | ផ្សព្វផ្សាយ សម្ភាស វាយតម្លៃ និងបណ្តុះបណ្តាល | ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងការិ. រដ្ឋបាល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | អេយូ | ដៃគូ |
|---|---|---|---|---|---|---|---|---|---|---|
| | - អ្នកគ្រប់គ្រងថ្នាក់កណ្តាលរួមមានៈ ព្រឹទ្ធបុរស នាយកវិទ្យាស្ថាន នាយកសាលាជាន់ខ្ពស់ និងប្រធានដេប៉ាតឺម៉ង់ មានសញ្ញាបត្របណ្ឌិតចំនួន ៥០ % ព្រមទាំងនាយកមជ្ឈមណ្ឌល បណ្ណាល័យ និងប្រធានការិយាល័យ ជាដើម មានសញ្ញាបត្របណ្ឌិតចំនួន ៣០% ភាគរយ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៧០% | ផ្សព្វផ្សាយ សម្ភាស វាយតម្លៃ និងបណ្តុះបណ្តាល | គណៈគ្រប់គ្រង | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | - អ្នកគ្រប់គ្រងថ្នាក់ក្រោមមានបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៥០% | ផ្សព្វផ្សាយ សម្ភាស វាយតម្លៃ និងបណ្តុះបណ្តាល | គណៈគ្រប់គ្រង មហាវិទ្យាល័យពាក់ព័ន្ធ និងការិ.រដ្ឋបាល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | - បុគ្គលិកប្រតិបត្តិការការងារជំនាញមានបរិញ្ញាបត្រចំនួន ៥០ភាគរយ និងបុគ្គលិកប្រតិបត្តិការការងារសន្តិសុខ និងអនាម័យមានកម្រិតវប្បធម៌សមស្រប | ផ្សព្វផ្សាយ សម្ភាស វាយតម្លៃ និងបណ្តុះបណ្តាល | គណៈគ្រប់គ្រង មហាវិទ្យាល័យពាក់ព័ន្ធ និងការិ. រដ្ឋបាល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | - អភិវឌ្ឍសមត្ថភាពដោយផ្តល់អាហារូបករណ៍ និងការចូលរួមសិក្ខាសាលា ដើម្បីសិក្សាបង្កើនគុណវុឌ្ឍិ និងពង្រីកសមត្ថភាពនៅក្នុង និងឬ ក្រៅប្រទេស/ | ផ្សព្វផ្សាយ សម្ភាស វាយតម្លៃ និងបណ្តុះបណ្តាល | គណៈគ្រប់គ្រង មហាវិទ្យាល័យពាក់ព័ន្ធ និងការិ. រដ្ឋបាល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | - ថ្នាក់ដឹកនាំនិងបុគ្គលិកសាកលវិទ្យាល័យមានសមត្ថភាពភាសាអង់គ្លេសអាចប្រើប្រាស់ជាផ្លូវការ ព្រមទាំងអាចប្រើប្រាស់ ICT យ៉ាងស្ទាត់ជំនាញ ។ | ផ្សព្វផ្សាយ សម្ភាស វាយតម្លៃ និងបណ្តុះបណ្តាល | ការិ.រដ្ឋបាល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | អេយូ | ដៃគូ |
|---|---|---|---|---|---|---|---|---|---|---|
| ការដឹកនាំ គ្រប់គ្រង និងអនុវត្ត ប្រកបដោយភាពច្បាស់លាស់ | - អនុវត្តការងារដោយរលូនស្របតាមតួនាទី និងភារកិច្ចរបស់បុគ្គលិកតាមលំដាប់ថ្នាក់ជាប្រចាំ | ស្រាវជ្រាវ ប្រមូលទិន្នន័យ វិភាគ និងកែលម្អ | គណៈគ្រប់គ្រង មហាវិទ្យាល័យពាក់ព័ន្ធ និង ការិ.រដ្ឋបាល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | - ប្រជុំសម្រាប់បង្កើតយន្តការងារដែលមានប្រសិទ្ធភាពខ្ពស់ក្នុងបរិបទបច្ចេកវិទ្យាទំនើបស្របតាមរចនាសម្ព័ន្ធច្បាស់លាស់ | រៀបចំ និងគ្រប់គ្រង តាមប្រព័ន្ធអនឡាញ | គណៈគ្រប់គ្រង មហាវិទ្យាល័យ ពាក់ព័ន្ធ ការិ. រដ្ឋបាល និងការិយាល័យ IT | ✓ | | | | | ✓ | |
| ការបង្កើត និងអភិវឌ្ឍយន្តការតាមដានត្រួតពិនិត្យ វាយតម្លៃ និងលើកទិសដៅ | - ពន្យល់ណែនាំពីគោលការណ៍នានាដែលពាក់ព័ន្ធនឹងការតាមដានត្រួតពិនិត្យដល់បុគ្គលិកក្រោមឱវាទ | ផ្សព្វផ្សាយ | គណៈគ្រប់គ្រង មហាវិទ្យាល័យ ពាក់ព័ន្ធ និងការិ. រដ្ឋបាល | ✓ | | | | | ✓ | |
| | - មានដំណើរការតាមដាន ត្រួតពិនិត្យ និងកែលម្អដល់បុគ្គលិកតាមលំដាប់ថ្នាក់ជាប្រចាំ | បង្កើតយន្តការកែលម្អ | គណៈគ្រប់គ្រង មហាវិទ្យាល័យពាក់ព័ន្ធ និងការិរដ្ឋបាល. | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | - វាយតម្លៃការអនុវត្តផែនការ និងលើកទិសដៅ ស្របតាមគោលការណ៍ និងនីតិវិធីរបស់សាកលវិទ្យាល័យ | រៀបចំ អនុម័ត កែលម្អនិងផ្សព្វផ្សាយ | គណៈគ្រប់គ្រង មហាវិទ្យាល័យពាក់ព័ន្ធ និងការិ.រដ្ឋបាល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | អេយូ | ដេគូ |
|---|---|---|---|---|---|---|---|---|---|---|
| ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពខ្ពស់ | - មានប្រព័ន្ធគណនេយ្យស្តង់ដារអន្តរជាតិកម្ពុជា | រៀបចំ និងអនុវត្ត | គណៈគ្រប់គ្រង និងការិ. គណនេយ្យ និងហិរញ្ញវត្ថុ | ✓ | | | | | | |
| | - មានគោលការណ៍ នីតិវិធី និងទម្រង់បែបបទស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ស្របតាមស្តង់ដារជាតិ និងអន្តរជាតិ | រៀបចំ អនុម័ត និង ផ្សព្វផ្សាយ សម្រាប់អនុវត្ត | គណៈគ្រប់គ្រង និងការិ. គណនេយ្យ និងហិរញ្ញវត្ថុ | ✓ | | | | | | |
| | - គ្រប់គ្រង និងប្រតិបត្តិការប្រព័ន្ធគណនេយ្យស្របតាមមានគោលការណ៍ នីតិវិធី និងទម្រង់បែបបទ | ដឹកនាំ អនុវត្ត និងតាមដាន | ការិ. គណនេយ្យ និងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | - មានរបាយការណ៍ហិរញ្ញវត្ថុ ស្របតាមស្តង់ដារជាតិ និងអន្តរជាតិ ច្បាស់លាស់ | រៀបចំ អនុម័ត កែលម្អនិង ផ្សព្វផ្សាយ | គណៈគ្រប់គ្រង និងការិ. គណនេយ្យ និងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | - ធ្វើសវនកម្មផ្ទៃក្នុង និងខាងក្រៅ ស្របតាមមានគោលការណ៍ និងនីតិវិធី ។ | ស្រាវជ្រាវ ប្រមូលទិន្នន័យ វិភាគ និងកែលម្អ | ការិ. សវនកម្ម | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | អេយូ | ដៃគូ |
|---|---|---|---|---|---|---|---|---|---|---|
| ២. ការបង្កើនគុណភាពអប់រំប្រកបដោយនិរន្តរភាព | | | | | | | | | | |
| ការអភិវឌ្ឍកម្មវិធីសិក្សាស្របតាមស្តង់ដាជាតិ និងអន្តរជាតិ | - មានសេចក្តីសម្រេចស្តីពីការរៀបចំ និងការអភិវឌ្ឍកម្មវិធីអប់រំកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយសម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងភាគី.ពាក់ព័ន្ធ | ✓ | | | | | ✓ | |
| | - សិក្សាស្រាវជ្រាវពីបញ្ហាប្រឈមរបស់ និស្សិតបញ្ចប់ការសិក្សានៃឯកទេសនីមួយៗ | ស្រាវជ្រាវ វិភាគ កែលម្អ និងផ្សព្វផ្សាយ | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងភាគី.ពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | - ស្រាវជ្រាវតម្រូវការទីផ្សារការងារពីសហគ្រិន ដូចជាស្ថាប័នរដ្ឋ ឯកជន អង្គការជាតិ និងអន្តរជាតិ | ស្រាវជ្រាវ វិភាគ កែលម្អ និងផ្សព្វផ្សាយ | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងភាគី. ពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | - អភិវឌ្ឍកម្មវិធីសិក្សា ស្របតាមគោលការណ៍និងនីតិវិធីស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា ដោយផ្សារភ្ជាប់ ការស្រាវជ្រាវជាមួយភាគីពាក់ព័ន្ធដូចជាគ្រូបង្រៀន និស្សិត និងទីផ្សារការងារ | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយសម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងភាគី. ពាក់ព័ន្ធ | ✓ | | | | ✓ | ✓ | |

| | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | អេឃ្យូ | ដៃគូ |
|---|---|---|---|---|---|---|---|---|---|---|
| | - បង្កើតកម្មវិធីសិក្សាឯកទេសថ្មីៗ គ្រប់កម្រិតស្របតាមគោលការណ៍និងនីតិវិធីស្តីពី ការអភិវឌ្ឍ កម្មវិធីសិក្សា ដោយផ្សារភ្ជាប់ការស្រាវជ្រាវជាមួយភាគីពាក់ព័ន្ធដូចជាគ្រូបង្រៀន និស្សិត និងទីផ្សារការងារ | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយសម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងការិ. ពាក់ព័ន្ធ | ✓ | ✓ | | | | ✓ | |
| | - ផលសម្រេចរំពឹងទុកនៃកម្មវិធីសិក្សាត្រូវឆ្លើយតបទៅនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ គោលនយោបាយអភិវឌ្ឍជាតិ ពាក់ព័ន្ធយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ ស្តង់ដាជាតិ និងភាគីពាក់ព័ន្ធដូចជាគ្រូបង្រៀន និស្សិត និងទីផ្សារការងារ | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយសម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងការិ. ពាក់ព័ន្ធ | ✓ | ✓ | ✓ | | | ✓ | |
| | - មានរចនាសម្ព័ន្ធនៃកម្មវិធីអប់រំសម្រាប់ឯកទេសនីមួយៗច្បាស់លាស់ | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយសម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងការិ. ពាក់ព័ន្ធ | ✓ | ✓ | ✓ | | | ✓ | |
| | -កំណត់ចំនួនក្រេឌីតច្បាស់លាស់លើកម្មវិធីសិក្សាសម្រាប់ឯកទេស សម្រាប់មុខវិជ្ជានីមួយៗ សិក្ខាសាលា សារណា និងនិក្ខេបបទ | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយសម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងការិ. ពាក់ព័ន្ធ | ✓ | | | | | ✓ | |

| | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | អេយូ | ដៃគូ |
|---|---|---|---|---|---|---|---|---|---|---|
| | -គ្រប់មុខវិជ្ជានៃកម្មវិធីអប់រំមានគម្រោងមុខវិជ្ជាច្បាស់លាស់ ដែលបញ្ជាក់អំពី ឈ្មោះគម្រោងមុខវិជ្ជា លេខកូដ មុខវិជ្ជា និងឈ្មោះមុខវិជ្ជា ចំនួនក្រេឌីត មុខវិជ្ជាតម្រូវសិក្សាមុន ការពិពណ៌នាមុខវិជ្ជា លទ្ធផលរំពឹងទុកនៃមុខវិជ្ជា ប្លង់មេរៀន វិធីសាស្ត្របង្រៀន វាយតម្លៃការសិក្សា សៀវភៅគោលនិងឯកសារយោង | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយ សម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងការិ. ពាក់ព័ន្ធ | ✓ | ✓ | ✓ | | | ✓ | |
| | - ប្លង់មេរៀន ឬផែនការបង្រៀនត្រូវឆ្លើយតបទៅនឹងផលសម្រេចរំពឹងទុកនៃមុខវិជ្ជានីមួយៗ | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយ សម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងការិ. ពាក់ព័ន្ធ | ✓ | ✓ | ✓ | | | ✓ | |
| | -មានលទ្ធផលរំពឹងទុកនៃមុខវិជ្ជានីមួយៗដែលឆ្លើយតបទៅនឹងផលសម្រេចរំពឹងទុករបស់កម្មវិធីសិក្សានៃឯកទេសនីមួយៗ | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយ សម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងការិ. ពាក់ព័ន្ធ | ✓ | ✓ | ✓ | | | ✓ | |
| | -កម្មវិធីអប់រំនៃឯកទេសនីមួយៗមានកំណត់អំពីលក្ខខណ្ឌនៃការជ្រើសរើសនិស្សិត និងការបញ្ចប់ការសិក្សា របស់និស្សិតច្បាស់លាស់ | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយ សម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា មហាវិទ្យាល័យ និងការិ. ពាក់ព័ន្ធ | ✓ | ✓ | ✓ | | | ✓ | |

| | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | អេឃ្យ | ដៃគូ |
|---|---|---|---|---|---|---|---|---|---|---|
| | -មុខវិជ្ជានីមួយៗនៃកម្មវិធីអប់រំមានសៀវភៅគោល ឬ សៀវភៅចងក្រងច្បាស់លាស់ដែលបានសំយោគចេញពីសៀវភៅយោងចំនួនយ៉ាងតិច ៣ ក្បាលផ្សេងគ្នា និងឬ / បទពិសោធ ឬ កិច្ចការស្រាវជ្រាវ/ស្នាដៃស្រាវជ្រាវ និង ការងារជាក់ស្តែង ស្របទៅតាមគម្រោងមុខវិជ្ជា | រៀបចំ ពិភាក្សា អនុម័ត និងផ្សព្វផ្សាយ សម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍ កម្មវិធីសិក្សា មហាវិទ្យាល័យ និងការិ. ពាក់ព័ន្ធ | ✓ | ✓ | ✓ | | | ✓ | |
| | - មានឯកសារយោងតម្កល់នៅបណ្ណាល័យស្របតាមគម្រោងមុខវិជ្ជា | រៀបចំ ពិភាក្សា និងអនុម័ត សម្រាប់អនុវត្ត | គណៈកម្មការអភិវឌ្ឍ កម្មវិធីសិក្សា មហាវិទ្យាល័យពាក់ព័ន្ធ ការិ. ចុះឈ្មោះ និងគ្រប់គ្រង ការិ .ស្រាវជ្រាវនិងបោះពុម្ពផ្សាយ និងបណ្ណាល័យ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | - មានគោលការណ៍ និងនីតិវិធីស្តីពីការប្រឡងចេញផ្ទៃក្នុង និងថ្នាក់ជាតិសម្រាប់ថ្នាក់បរិញ្ញាបត្រនិងបរិញ្ញាបត្ររងនៃមហាវិទ្យាល័យសុខភាពសាធារណៈ | រៀបចំ ពិភាក្សា និង អនុម័ត សម្រាប់អនុវត្ត | គណៈគ្រប់គ្រង គណៈកម្មការអភិវឌ្ឍ កម្មវិធីសិក្សា មហាវិទ្យាល័យ និងការិ. ពាក់ព័ន្ធ | ✓ | ✓ | | | | ✓ | |

| | លទ្ធផលរំពឹងទុក | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | អេយូ | ដៃគូ |
